Peace Corps
CAMBODIA




# របាយការណ៍ប្រចាំឆ្នាំ

# ២០២៣

សន្តិភាព និងមិត្តភាពពិភពលោក

**ទីភ្នាក់ងារ ភីស ខ័រ កម្ពុជា**

ផ្ទះលេខ ៧អា ផ្លូវលេខ ២៥៦
រាជធានីភ្នំពេញ ប្រអប់សំបុត្រលេខ ២៤៥៣
ទូរស័ព្ទលេខ៖ (៨៥៥) ២៣ ២២២ ៩០១
ទូរសារលេខ៖ (៨៥៥) ២៣ ២២២ ៩០៣
អ៊ីម៉ែល៖ KH-WebInfo@peacecorps.gov

**PC Facebook:** **PC Instagram:** **PC Website:**

**ខែមករា ឆ្នាំ ២០២៤**

ទីភ្នាក់ងារ ភីស ខ័រ គឺជាស្ថាប័នដែលមិនប្រកាន់និន្នាការនយោបាយ និងសាសនា របស់រដ្ឋាភិបាលសហរដ្ឋអាមេរិក ដែលធ្វើការដើម្បីលើកកម្ពស់សន្តិភាព និងមិត្តភាព រវាងប្រជាជននៃប្រទេស និងវប្បធម៌ផ្សេងគ្នា។ អស់រយៈពេលជាង ប្រាំមួយទសវត្សរ៍កន្លងទៅនេះ ទីភ្នាក់ងារ ភីស ខ័រ បានផ្តល់ជំនួយបច្ចេកទេសដល់ប្រទេស ចំនួន ១៤១ តាមរយៈ ការអនុវត្តគម្រោង កសិកម្ម ការអភិវឌ្ឍសេដ្ឋកិច្ចសហគមន៍ ការអប់រំ បរិស្ថាន សុខភាព និងការអភិវឌ្ឍយុវជន។

# មាតិកានុក្រម

សារពីនាយិកាប្រចាំប្រទេស ២
ទស្សនៈរួមជាសកលនៃទីភ្នាក់ងារភីស ខ័រ ៣
ការគាំទ្ររបស់រាជរដ្ឋាភិបាលកម្ពុជា ៤
ទីភ្នាក់ងារភីស ខ័រ នៅកម្ពុជា ៦
ការបង្រៀនភាសាអង់គ្លេស និង ការបណ្តុះបណ្តាលគ្រូ ៧
សមិទ្ធផលសម្រេចបានពីកម្មវិធីអប់រំក្នុងឆ្នាំ ២០២៣ ៨
ការបណ្តុះបណ្តាលនានា ១០
សិក្ខាសាលាស្តីពី កិច្ចសហការរវាងអ្នកស្ម័គ្រចិត្ត ភីស ខ័រ ជាមួយគ្រូដៃគូ ១០
ពិធីសំណេះសំណាលជាមួយគ្រួសារខ្មែរ ១២
គំនិតផ្តួចផ្តើមថ្មី ១៤
គម្រោងគាំទ្រកម្មវិធី អ្នកស្ម័គ្រចិត្តដើម្បីសហគមន៍ខ្ញុំ (ស.ស.ខ) ១៤
សមិទ្ធផលសម្រេចបានពីគម្រោង ១៥
ដំណើររឿងរបស់អ្នកស្ម័គ្រចិត្ត ១៨
ម៉េហ្គិន ហ័រនឺរ (Megan Horner) និងអ្នកគ្រូ នីតា ដែលជាគ្រូដៃគូរបស់គាត់ នៅខេត្តកំពង់ធំ ១៨
អេថិន ស្មីត (Ethan Smith) និងសិស្សរបស់គាត់នៅខេត្តកំពង់ចាម ២០
ខេធី អូស៊ូលីវ៉ិន (Katie O’Sullivan) និងក្លឹបភាសាអង់គ្លេសក្រៅម៉ោងសិក្សារបស់គាត់នៅខេត្តបន្ទាយមានជ័យ ២២
ជេក អាប់ថិន (Jake Upton) និងបទពិសោធន៍ជាមួយគ្រួសារខ្មែរ និងសហគមន៍នៅខេត្តកំពង់ឆ្នាំង ២៤

# សារពី

# នាយិកាប្រចាំប្រទេស



បេសកកម្មរបស់ទីភ្នាក់ងារភីស ខ័រ គឺ ***"សន្តិភាព និង មិត្តភាពពិភពលោក។"*** យើងបំពេញបេសកកម្មរបស់យើងតាមរយៈការបម្រើសេវាកម្មជាអ្នកស្ម័គ្រចិត្ត។ អ្នកស្ម័គ្រចិត្តរបស់យើងរស់នៅនិងធ្វើការរយៈពេលពីរឆ្នាំនៅក្នុងសហគមន៍ជាមួយគ្រួសារខ្មែរ ដើម្បីជ្រួតជ្រាប និង សម្របខ្លួនតាម វប្បធម៌ក្នុងមូលដ្ឋាន។ ប្រការនេះនឹង ជួយឲ្យពួកគេបង្កើតបាននូវទំនាក់ទំនងប្រកបដោយអត្ថន័យ មើលឃើញពីទស្សនៈថ្មីមួយ និងរួមចំណែកដល់ការអភិវឌ្ឍកម្ពុជា និងប្រើប្រាស់ជំនាញបច្ចេកទេសរបស់ពួកគេយ៉ាងសមស្រប នៅក្នុងបរិស្ថាន និង វប្បធម៌ថ្មី។

អ្នកស្ម័គ្រចិត្តបានវិលត្រឡប់មកកម្ពុជាវិញកាលពីឆ្នាំមុននៅពេលដែលកម្មវិធីបានចាប់ផ្តើមឡើងវិញក្រោយពីការផ្អាកដំណើរការជាងពីរឆ្នាំ ដោយសារការរីករាលដាលនៃជំងឺកូវីដ។ ពួកគេបាននឹងកំពុងធ្វើការជាមួយគ្រូបង្រៀននៅទូទាំងប្រទេស ដើម្បីរួមចំណែកដល់ការអភិវឌ្ឍការអប់រំភាសាអង់គ្លេស នៅកម្ពុជា។ លើសពីនេះ ពួកគេបានធ្វើការជាមួយសហការី និង មិត្តភក្តិក្នុងស្រុក លើគម្រោងអភិវឌ្ឍន៍ សហគមន៍ផ្សេងៗជាច្រើន ដូចជាការអភិវឌ្ឍសួនដំណាំសាលា ដែលជួយកែលម្អអាហារូបត្ថម្ភរបស់កុមារនិងគ្រួសារ ឬការបង្កើតបណ្ណាល័យមួយ ដែលជាធនធានមួយសម្រាប់សាលារៀន និង សហគមន៍។

មិនថាពួកគេធ្វើការជាគ្រូបង្រៀន ឬជាមួយសហគមន៍លើគម្រោងអភិវឌ្ឍន៍មួយក្តី ក៏គោលដៅគឺជាការកសាងសមត្ថភាពក្នុងមូលដ្ឋានដែរ។ តាមរយៈធ្វើការជាមួយអ្នកស្ម័គ្រចិត្ត សមាជិកសហគមន៍ អាចរៀនសូត្រដើម្បីកំណត់សមត្ថភាពជាអ្នកដឹកនាំ រៀនរកធនធាន និងរៀនអនុវត្តការធ្វើការរួមគ្នាឆ្ពោះទៅកាន់គោលដៅអភិវឌ្ឍន៍សហគមន៍ ដែលបំពេញតាមសេចក្តីត្រូវការ និងកាលានុវត្តភាពនានាដែលបានកំណត់ជាអាទិភាពដោយសហគមន៍។ តួនាទីរបស់អ្នកស្ម័គ្រចិត្ត គឺចូលរួមជាសមាជិកថ្មីមួយរូបនៃសហគមន៍ និងជួយសម្រួលកិច្ចដំណើរការនេះ។

នៅពេលធ្វើការ និងរស់នៅក្នុងសហគមន៍ អ្នកស្ម័គ្រចិត្តរបស់យើងក៏ចែករំលែកផងដែរនូវវប្បធម៌និងទំនៀមទម្លាប់ផ្សេងៗរបស់សហរដ្ឋអាមេរិក ដើម្បីជួយឲ្យប្រសើរឡើងនូវទំនាក់ទំនងរវាងប្រជាជននៃប្រទេសទាំងពីរ។ អ្នកស្ម័គ្រចិត្តអាចចែករំលែកអំពីវប្បធម៌ និង ប្រពៃណីដ៏សម្បូណ៌បែបនៃប្រទេសកម្ពុជាដែលពួកគេបានរៀន ទៅកាន់គ្រួសារ និងមិត្តភក្តិនៅសហរដ្ឋអាមេរិក។ មិត្តភាពដែលបានបង្កើតឡើងក្នុងអំឡុងពេលពីរឆ្នាំនៃការរស់នៅ និងធ្វើការនៅក្នុងសហគមន៍នៅកម្ពុជាតាមរយៈការចែករំលែកគ្នានេះ អាចស្ថិតស្ថេរពេញមួយជីវិត និងជាកម្លាំងជំរុញនៅពីក្រោយបេសកកម្មយើងក្នុងការកសាង សន្តិភាព និង មិត្តភាពពិភពលោក។

យើងបន្តថ្លែងអំណរគុណចំពោះភាគីម្ចាស់ផ្ទះ ពោលគឺរាជរដ្ឋាភិបាលកម្ពុជា ដែលធ្វើឲ្យកិច្ចសហការនេះអាចដំណើរការបាន តាមរយៈការអញ្ជើញទីភ្នាក់ងារភីស ខ័រ ឲ្យមកធ្វើការក្នុងភាពជាដៃគូ ដើម្បីបំពេញគម្រោងអភិវឌ្ឍន៍ដែលជាអាទិភាពរបស់រាជរដ្ឋាភិបាលកម្ពុជា នៅថ្នាក់ជាតិ ខេត្ត ស្រុក និងឃុំ។ របាយការណ៍ប្រចាំឆ្នាំនេះ ក៏ចូលរួមអបអរសាទរខួប ១៥ ឆ្នាំនៃកិច្ចសហការជាមួយមន្ត្រី សមភាគី ដៃគូអ្នកមានវិជ្ជាជីវៈកម្ពុជានៅក្នុងគ្រឹះស្ថានអប់រំនានា និងការកសាងទំនាក់ទំនងជាមួយគ្រួសារខ្មែរក្នុងកម្រិតសហគមន៍ និង ជាលក្ខណៈបុគ្គល។

ទិន្នន័យ និងដំណើររឿងដែលចែករំលែកនៅក្នុងរបាយការណ៍ប្រចាំឆ្នាំ២០២៣ នេះ តំណាងឲ្យស្មារតីនៃយុទ្ធសាស្ត្រអភិវឌ្ឍន៍រវាងមនុស្ស និងមនុស្សរបស់ទីភ្នាក់ងារភីស ខ័រ ដែលអាចកើតឡើងបានតែនៅពេលដែលយើងរៀនសូត្រ និងរីកចម្រើនរួមគ្នាតែប៉ុណ្ណោះ។ យើងមានមោទកនភាពក្នុងការចែករំលែកសមិទ្ធផលសហការរបស់អ្នកស្ម័គ្រចិត្តរបស់យើង និងសមភាគីកម្ពុជានៅក្នុងឆ្នាំ ២០២៣ តាមរយៈរបាយការណ៍ប្រចាំឆ្នាំនេះ។



# ទស្សនៈរួមជាសកលនៃទីភ្នាក់ងារ ភីស ខ័រ

ទីភ្នាក់ងារ ភីស ខ័រ បញ្ជូនជនជាតិអាមេរិក ប្រកបដោយចំណេះដឹងដែលជាតំណាងឲ្យសហរដ្ឋអាមេរិកទៅក្រៅប្រទេសដើម្បីចូលរួមជួយដោះស្រាយតម្រូវការចាំបាច់បំផុតរបស់ប្រជាជននៅជុំវិញពិភពលោក។ អ្នកស្ម័គ្រចិត្ត ធ្វើការនៅតាមកម្រិតមូលដ្ឋានដើម្បីអភិវឌ្ឍដំណោះស្រាយប្រកបដោយនិរន្តរភាព ដែលដោះស្រាយបញ្ហាប្រឈមនានានៅក្នុងវិស័យកសិកម្ម ការអភិវឌ្ឍសេដ្ឋកិច្ចសហគមន៍ ការអប់រំ បរិស្ថាន សុខភាព និងការអភិវឌ្ឍយុវជន។ តាមរយៈសេវាកម្មរបស់ពួកគេ អ្នកស្ម័គ្រចិត្តទទួលបាននូវការយល់ដឹងពីវប្បធម៌ដោយឡែក ជាមួយនឹងការប្តេជ្ញាចិត្តក្នុងមួយជីវិតរបស់គេក្នុងការបម្រើការងារដែលអាចឲ្យពួកគេស្ថិតក្នុងតួនាទីមួយដែលនាំឲ្យពួកគេទទួលបានភាពជោគជ័យក្នុងសង្គមនាពេលបច្ចុប្បន្ននិងអនាគត។

ទីភ្នាក់ងារ បានចាប់កំណើតតាំងពីឆ្នាំ ១៩៦០ នៅពេលដែលអតីតសមាជិកព្រឹទ្ធសភា ចន អេហ្វ កេណេឌី (John F. Kennedy) បានជំរុញឲ្យនិស្សិតនៅសកលវិទ្យាល័យមីឈីហ្គេន (University of Michigan) ទៅរស់នៅ និងធ្វើការនៅទីកន្លែងឆ្ងាយដាច់ស្រយាលបំផុតនៅលើពិភពលោក។ លោកបានជំរុញយុវជនអាមេរិកាំង និងប្រទេសជាតិទាំងមូល ដោយឈានដល់ការបង្កើតទីភ្នាក់ងារភីស ខ័រ នេះឡើង។ នៅក្នុងពិភពលោកមួយដែលប្រែប្រួលមិនឈប់ឈរ ទីភ្នាក់ងារនេះបានក្លាយជាទីភ្នាក់ងារឆ្នើម និងប្រកបដោយថាមភាព និងដើរឆ្ពោះទៅមុខ ក្នុងវិស័យសេវាកម្មអន្តរជាតិដោយសារគំនិតច្នៃប្រឌិតថ្មី និងមេត្តាធម៌របស់ខ្លួន ប៉ុន្តែ បេសកកម្មដំបូងរបស់ទីភ្នាក់ងារគឺស្ថិតនៅដដែល។

ប្រាំមួយទសវត្សក្រោយពេលបង្កើតដោយប្រធានាធិបតី ចន អេហ្វ កេណេឌី (John F. Kennedy) ទីភ្នាក់ងារភីស ខ័រ នៅតែតាំងចិត្តខ្ពស់ចំពោះ ការលើកកម្ពស់សន្តិភាព និងការកសាងមិត្តភាពពិភពលោក ដោយដើរតាមគោលដៅចំនួនបី។



១

ផ្តល់អ្នកស្ម័គ្រចិត្ត ទាំងបុរស និង ស្ត្រី ដែលបានទទួលការបណ្តុះបណ្តាល ទៅចូលរួម ជួយប្រជាជននៅក្នុងបណ្តាប្រទេសដែលចាប់អារម្មណ៍ លើទីភ្នាក់ងារភីស ខ័រ ។



២

ជួយអ្នកស្ម័គ្រចិត្តអាមេរិកាំងអោយមានការយល់ដឹងកាន់តែប្រសើរឡើង អំពីប្រជាជនដែលពួកគេធ្វើការជាមួយ ។



៣

ជួយអោយប្រជាជាតិដទៃមានការយល់ដឹងកាន់តែប្រសើរឡើង អំពីជនជាតិអាមេរិកាំង។

# ការគាំទ្ររបស់រាជរដ្ឋាភិបាល កម្ពុជា

ភាពជាដៃគូជាមួយរាជរដ្ឋាភិបាលកម្ពុជា គឺជាគ្រឹះនៃការងារភាគច្រើនរបស់ភីស ខ័រ កម្ពុជា។ ភាពជាដៃគូរបស់យើងបានចាប់ផ្តើមជាមួយក្រសួងអប់រំ យុវជន និងកីឡា អនុលោមតាមអនុស្សរណៈនៃការយោគយល់ឆ្នាំ ២០០៧ ដើម្បីបញ្ជូនអ្នកស្ម័គ្រចិត្តភីស ខ័រ ទៅកាន់សាលាមធ្យមសិក្សាដើម្បីផ្តល់ការគាំទ្រការបង្រៀនភាសាអង់គ្លេស។

ក្រសួងអប់រំ យុវជន និងកីឡា បានផ្តល់ការណែនាំលើទិសដៅយុទ្ធសាស្ត្រ និងទីតាំងភូមិសាស្ត្រ សម្រាប់ទីភ្នាក់ងារភីស ខ័រ កម្ពុជា។ មន្ត្រីថ្នាក់ខេត្តនិងស្រុក ជួយកំណត់ទីតាំងដាក់ពង្រាយអ្នកស្ម័គ្រចិត្ត។ អ្នកស្ម័គ្រចិត្តភីស ខ័រ ស្ថិតក្រោមការគ្រប់គ្រង និងណែនាំពីគណៈគ្រប់គ្រងសាលា។ក្នុងឆ្នាំ២០១៩ក្រោមចក្ខុវិស័យរបស់ក្រសួងអប់រំយុវជននិងកីឡាទីភ្នាក់ងារភីស ខ័រ កម្ពុជាបានពង្រីកវិសាលភាពលើការអប់រំភាសាអង់គ្លេសរបស់ខ្លួន ដោយដាក់ពង្រាយអ្នកស្ម័គ្រចិត្តនៅតាមសាលាបឋមសិក្សា ដើម្បីធ្វើការជាមួយគ្រូនិងសិស្សនៅថ្នាក់ទី៤ ទី៥ និងទី៦។ ដោយមានការគាំទ្រនិងការណែនាំចង្អុលបង្ហាញជាបន្តបន្ទាប់របស់ក្រសួង យើងសង្ឃឹមថានឹងបង្កើនចំនួនអ្នកស្ម័គ្រចិត្តដែលត្រូវដាក់ពង្រាយនៅតាមសាលាបឋមសិក្សាសម្រាប់បណ្តាឆ្នាំខាងមុខនេះ។

ក្រសួងការបរទេស និងកិច្ចសហប្រតិបត្តិការអន្តរជាតិ ផ្តល់ការអនុញ្ញាតឲ្យទីភ្នាក់ងារភីស ខ័រ ធ្វើការនៅកម្ពុជា និងផ្តល់ទិដ្ឋាការសម្រាប់អ្នកស្ម័គ្រចិត្ត។ ក្រសួងមហាផ្ទៃនៅថ្នាក់ជាតិ ខេត្ត ស្រុក និងឃុំ ជួយពួកយើងក្នុងការរក្សាសុវត្ថិភាពជូនអ្នកស្ម័គ្រចិត្ត និងផ្តល់ការគាំទ្រសង្គ្រោះបន្ទាន់។

ទីភ្នាក់ងារភីស ខ័រ កម្ពុជា សូមថ្លែងអំណរគុណចំពោះការណែនាំ ទំនាក់ទំនងសហប្រតិបត្តិការ និងការលើកទឹកចិត្តរបស់រាជរដ្ឋាភិបាលកម្ពុជា។


ពិធីសច្ចាប្រណិធានអ្នកស្ម័គ្រចិត្ត K15


ពិធីសច្ចាប្រណិធានអ្នកស្ម័គ្រចិត្ត K14


ជំនួបប្រជុំជាមួយក្រសួងអប់រំ យុវជន និងកីឡា


ពិធីសច្ចាប្រណិធានអ្នកស្ម័គ្រចិត្ត K14

# ទីភ្នាក់ងារភីស ខ័រ នៅកម្ពុជា

បុគ្គលទាំងឡាយដែលបំពេញការងារជាអ្នកស្ម័គ្រចិត្តភីស ខ័រ ត្រូវបានជ្រើសរើសយ៉ាងមធ្យ័ត តាមរយៈការដាក់ពាក្យសុំដែលប្រកបដោយភាពប្រកួតប្រជែង។ អ្នកស្ម័គ្រចិត្តភីស ខ័រ មានអាយុចាប់ពី ២០ ឆ្នាំ ដល់ ៧៥ ឆ្នាំ និងតំណាងឲ្យក្រុមជនជាតិ និងសាសន៍ផ្សេងៗគ្នា។ អ្នកស្ម័គ្រចិត្តភីស ខ័រ ទាំងអស់នៅក្នុងប្រទេសកម្ពុជានាពេលបច្ចុប្បន្ន មានសញ្ញាបត្រកម្រិតបរិញ្ញាបត្រ និង/ឬសញ្ញាបត្រជាន់ខ្ពស់។ អ្នកស្ម័គ្រចិត្តមកកម្ពុជាដើម្បីចូលរួមវិភាគទានប្រើប្រាស់ជំនាញ និងចំណេះដឹងរបស់ពួកគេចំពោះការអភិវឌ្ឍប្រទេសកម្ពុជា តាមរយៈសកម្មភាពផ្ទាល់នៅកម្រិតមូលដ្ឋាន។ នៅពេលមកដល់កម្ពុជា អ្នកស្ម័គ្រចិត្តភីស ខ័រ ទទួលបានការបណ្តុះបណ្តាលជាច្រើនទៅលើ ផ្នែកភាសា វប្បធម៌ សុខភាព សុវត្ថិភាព និងបច្ចេកទេស។ ក្នុងអំឡុងពេលនៃការបម្រើការងារជាអ្នកស្ម័គ្រចិត្ត ទីភ្នាក់ងារភីស ខ័រ បន្តបណ្តុះបណ្តាល បន្ថែមទៅលើ ភាសាខ្មែរ និងជំនាញបច្ចេកទេស។ ទីភ្នាក់ងារភីស ខ័រ ក៏បានផ្តល់ការបណ្តុះបណ្តាលចំពោះសមាជិកសហគមន៍ និងគ្រូបង្រៀនទៅលើប្រធានបទនានា ដូចជាការគ្រប់គ្រងគម្រោង សន្តិសុខស្បៀង វិធីសាស្ត្របង្រៀន និងអក្ខរកម្មឌីជីថល។

អ្នកស្ម័គ្រចិត្ត រស់នៅជាមួយគ្រួសារខ្មែរដែលមានកម្រិតជីវភាពប្រហាក់ប្រហែលនឹងប្រជាជនកម្ពុជានៅក្នុងសហគមន៍ដែលពួកគេរស់នៅរយៈពេលពីរឆ្នាំ។ ពួកគេធ្វើការ ជាមួយប្រជាជនកម្ពុជា ដើម្បីជួយពួកគេក្នុងការបំពេញការងារប្រកបដោយអត្ថន័យឆ្ពោះទៅកាន់អនាគតមួយកាន់តែប្រសើរឡើងសម្រាប់សហគមន៍ពួកគេ និងសម្រាប់កម្ពុជាទាំងមូល។

**អ្នកស្ម័គ្រចិត្តបច្ចុប្បន្ន**




**ចំនួនអ្នកស្ម័គ្រចិត្តៈ ៦៨ នាក់**




**គម្រោង**

| | |
|---|---|
| ២២ | សាលាបឋមសិក្សា |
| ៤២ | សាលាមធ្យមសិក្សា |
| ០៤ | មជ្ឈមណ្ឌលគរុកោសល្យ |

**អាយុ**




*អ្នកស្ម័គ្រចិត្តចំនួន ៦៨ នាក់កំពុងបម្រើការងារនៅក្នុង ១២ ខេត្ត នៅទូទាំងកម្ពុជា។*

# ការបង្រៀនភាសាអង់គ្លេស និង ការបណ្តុះបណ្តាលគ្រូ

គម្រោងបង្រៀនភាសាអង់គ្លេស និងបណ្តុះបណ្តាលគ្រូ បាននឹងកំពុងសហការជាមួយក្រសួងអប់រំ យុវជន និងកីឡា នៅកម្ពុជាចាប់តាំងពីឆ្នាំ ២០០៧។ គម្រោងនេះ បានធ្វើការដើម្បីអភិវឌ្ឍភាសាអង់គ្លេសរបស់សិស្ស គ្រូបង្រៀន និងសមាជិកសហគមន៍កម្ពុជា ដើម្បីជួយពួកគេឲ្យទទួលបានឱកាសផ្ទាល់ខ្លួន ឱកាសការងារ និងឱកាសសិក្សា។

អ្នកស្ម័គ្រចិត្តបង្រៀននៅសាលាមធ្យមសិក្សា និងសាលាបឋមសិក្សា និងមជ្ឈមណ្ឌលគរុកោសល្យ។ អ្នកស្ម័គ្រចិត្តសហការបង្រៀនជាមួយគ្រូខ្មែរ តាមសំណើរបស់ក្រសួងអប់រំ យុវជន និងកីឡា។ ការអនុវត្តបែបនេះ ផ្តល់អត្ថប្រយោជន៍មិនត្រឹមតែដល់សិស្សប៉ុណ្ណោះទេ ប៉ុន្តែ ថែមទាំងលើកកម្ពស់សមត្ថភាពភាសារបស់គ្រូបង្រៀន និងបង្កើនជំនាញបច្ចេកទេសគ្រប់គ្រងថ្នាក់រៀនទៀតផង។ ដោយបង្រៀនរួមគ្នាជាមួយគ្រូជនជាតិខ្មែរ អ្នកស្ម័គ្រចិត្តចែករំលែកវិធីសាស្ត្របង្រៀនបែបទំនើប ជួយរៀបចំ និងបង្រៀនមេរៀន បង្កើនជំនាញភាសាអង់គ្លេសសម្រាប់ទំនាក់ទំនង និងណែនាំឲ្យស្គាល់ពីបច្ចេកទេសគ្រប់គ្រងថ្នាក់រៀនប្រកបដោយប្រសិទ្ធភាព។ អ្នកស្ម័គ្រចិត្ត បានអភិវឌ្ឍនិងបង្កើនធនធានបង្រៀន និងរៀនសម្រាប់ថ្នាក់រៀន រួមទាំងការណែនាំឲ្យស្គាល់បច្ចេកវិទ្យាថ្មី។

ចាប់តាំងពីគម្រោងបានចាប់ផ្តើមក្នុងឆ្នាំ ២០០៧ មក មានអ្នកស្ម័គ្រចិត្តចំនួនច្រើនជាង ៧៨៥ នាក់ ដែលអ្នកស្ម័គ្រចិត្តចំនួន ៥៤៧ នាក់ គឺជាគ្រូបង្រៀនភាសាអង់គ្លេសនៅតាមសាលា និងជាគ្រូឧទ្ទេសនៅគ្រឹះស្ថានបណ្តុះបណ្តាលគ្រូ។

**គោលបំណងគម្រោង**

សិស្សានុសិស្សកម្ពុជា ទទួលបានជំនាញទំនាក់ទំនងជាភាសាអង់គ្លេស និងបំណិនជីវិតដែលចាំបាច់ដើម្បីទទួលបានឱកាសសិក្សា និងឱកាសការងារ។

**គោលដៅគម្រោង**

**១. គ្រូបង្រៀន គ្រូឧទ្ទេស និងគរុសិស្ស**

- ពង្រឹងសមត្ថភាពគ្រូបង្រៀន គ្រូឧទ្ទេស និងគរុសិស្សក្នុងការប្រើប្រាស់ជំនាញបង្រៀនភាសាអង់គ្លេសទូទៅឲ្យកាន់តែមានប្រសិទ្ធភាព។
- ពង្រឹងជំនាញភាសាអង់គ្លេសរបស់គ្រូបង្រៀនភាសាអង់គ្លេស គ្រូឧទ្ទេស និងគរុសិស្ស។
- ពង្រឹងសមត្ថភាពរបស់គ្រូបង្រៀន គ្រូឧទ្ទេស និងគរុសិស្សក្នុងការប្រើប្រាស់វិធីសាស្ត្រ ប្រកបដោយសមធម៌យេនឌ័រនៅក្នុងថ្នាក់រៀន។

**២. សិស្ស**

- ពង្រឹងសមិទ្ធផលភាសាអង់គ្លេសរបស់សិស្ស។
- ពង្រឹងបំណិនជីវិតរបស់សិស្ស។

**៣. បរិស្ថានសិក្សា**

- កែលម្អបរិស្ថានសិក្សារបស់សាលារៀន តាមរយៈការកែលម្អសាលារៀន ការចូលរួមរបស់សហគមន៍ឲ្យកាន់តែច្រើនឡើង និងការអភិវឌ្ឍធនធានសិក្សា។

# សមិទ្ធផលសម្រេចបានពី
# កម្មវិធីអប់រំក្នុងឆ្នាំ ២០២៣

**៦៨**

ចំនួនអ្នកស្ម័គ្រចិត្តដែលកំពុងបម្រើការងារ

ចំនួនខេត្តដែលអ្នកស្ម័គ្រចិត្តបម្រើការងារនៅក្នុងប្រទេស **កម្ពុជា**

**១២** ខេត្ត

**ពង្រឹង**សមត្ថភាពរបស់គ្រូក្នុងការប្រើប្រាស់ភាសាអង់គ្លេស ជំនាញបង្រៀនទូទៅ និងជំនាញភាសាអង់គ្លេសរបស់គ្រូបង្រៀនភាសាអង់គ្លេស

**៩៩**នាក់ ចំនួនគ្រូដៃគូដែលបានសហការធ្វើកិច្ចតែងការ និងបង្រៀនភាសាអង់គ្លេសរួមគ្នាជាមួយអ្នកស្ម័គ្រចិត្ត

**៦០%** ភាគរយនៃគ្រូដៃគូដែលបានបង្ហាញចំនួនអប្បបរមានៃការបង្រៀនដែលត្រូវបានទទួលស្គាល់លើជំនាញបង្រៀនទូទៅនិងជំនាញបង្រៀនភាសាអង់គ្លេស

English

**៥៧%** ភាគរយនៃគ្រូដែលបានពង្រឹងការប្រើប្រាស់ជំនាញភាសាអង់គ្លេសរបស់ខ្លួន

**ពង្រឹង**សមិទ្ធផលរបស់សិស្សលើភាសាអង់គ្លេស និងបំណិនជីវិតរបស់សិស្ស

**២៥៩**នាក់ ចំនួនថ្នាក់រៀនដែលអ្នកស្ម័គ្រចិត្តបានបង្រៀន

ចំនួនសិស្សដែលត្រូវបានបង្រៀនមេរៀនភាសាអង់គ្លេសដោយអ្នកស្ម័គ្រចិត្ត

**១០.៣៣១**នាក់ (ស្រ្តី ៥.៦៣៤ នាក់)

**៤៤៣**នាក់ ចំនួនសិស្សដែលបានចូលរួមសកម្មភាពក្លឹបរៀនភាសាអង់គ្លេសជាមួយអ្នកស្ម័គ្រចិត្ត

**៥៣%** ភាគរយនៃសិស្សដែលបានបង្ហាញសមិទ្ធផលនៅក្នុងការរៀនភាសាអង់គ្លេស

**បង្កើន**លទ្ធភាពរបស់សមាជិកសហគមន៍ក្នុងការគាំទ្រលទ្ធភាពរបស់សិស្សក្នុងការទទួលបានការសិក្សាដោយការកែលម្អបរិស្ថានសិក្សារបស់សាលា

**៦០៨**នាក់ ចំនួនសមាជិកសហគមន៍ដែលបានចូលរួមក្នុងគម្រោងកែលម្អបរិក្ខាសាលា

**៦៨%** ភាគរយនៃសមាជិកសហគមន៍ដែលរាយការណ៍ថា សកម្មភាពចូលរួមក្នុងគម្រោងសាលាដែលរៀបចំដោយអ្នកស្ម័គ្រចិត្ត បានបង្កើនលទ្ធភាពរបស់ពួកគេក្នុងការគាំទ្រលទ្ធភាពរបស់សិស្សក្នុងការទទួលបានការសិក្សា

Peace Corps CAMBODIA

# ការបណ្តុះបណ្តាលនានា

## សិក្ខាសាលាស្តីពី កិច្ចសហការរវាងអ្នកស្ម័គ្រចិត្ត ភីស ខ័រ ជាមួយគ្រូដៃគូ

ទីភ្នាក់ងារភីស ខ័រ កម្ពុជាបានរៀបចំសិក្ខាសាលាបណ្តុះបណ្តាលរយៈពេល ២ ថ្ងៃជូនគ្រូដៃគូរបស់អ្នកស្ម័គ្រចិត្ត ចំនួន ៧២ នាក់ ដែលបង្រៀននៅសាលាបឋមសិក្សាមកពីខេត្តបាត់ដំបង សៀមរាប ពោធិ៍សាត់ កំពង់ឆ្នាំង តាកែវ កំពត កំពង់ធំ ត្បូងឃ្មុំ កំពង់ចាម និងស្វាយរៀង។ អ្នកចូលរួម បានទទួលការបណ្តុះបណ្តាលលើផ្នែកបច្ចេកទេសស្តីអំពីគរុកោសល្យ បង្រៀនភាសាអង់គ្លេសនៅសាលាបឋមសិក្សា ដែលរួមបញ្ចូលនូវការគ្រប់គ្រងថ្នាក់រៀនជំនាញទាំងបួន ការធ្វើកិច្ចតែងការ វិធីសាស្ត្របង្រៀនរួមគ្នានិងការដាក់បញ្ចូលនូវល្បែងសិក្សានិងសកម្មភាពផ្សេងៗនៅក្នុងកិច្ចតែងការនិងលំនាំនៃការបង្រៀន។ លើសពីនេះទៅទៀតអ្នកចូលរួមដែលជាគ្រូដៃគូក៏មានឱកាសបង្រៀនសាកល្បងជាមួយអ្នកស្ម័គ្រចិត្តភីសខ័រដែរដើម្បីជាបទពិសោធន៍នៅសាលាគោលដៅរបស់ខ្លួន ។

ក្នុងឆ្នាំ ២០២៣ លោកបណ្ឌិត កាន់ ពុទ្ធី អនុប្រធាននាយកដ្ឋានបឋមសិក្សា បានចូលរួមបើកវគ្គបណ្តុះបណ្តាលស្តីអំពីវិធីសាស្ត្របង្រៀនភាសាអង់គ្លេសកម្រិតបឋមសិក្សា បញ្ហាប្រឈម និងដំណោះស្រាយនានាដល់បញ្ហាដែលអាចកើតមាន។



ការបង្កើនជំនាញបច្ចេកទេសបង្រៀនអង់គ្លេសសម្រាប់គ្រូដៃគូរបស់អ្នកស្ម័គ្រចិត្តក្រុមទី១៤



ការបង្កើនជំនាញបច្ចេកទេសបង្រៀនអង់គ្លេសសម្រាប់គ្រូដៃគូរបស់អ្នកស្ម័គ្រចិត្តក្រុមទី១៤

## ពិធីសំណេះសំណាលជាមួយគ្រួសារខ្មែរ

គ្រួសារម្ចាស់ផ្ទះរបស់យើងបានដើរតួនាទីយ៉ាងសំខាន់ក្នុងការផ្តល់ការគាំទ្រដល់អ្នកស្ម័គ្រចិត្តនៅកម្ពុជា។ ពួកគេមានសារៈសំខាន់ក្រៃលែងចំពោះការធ្វើសមាហរណកម្មវប្បធម៌ និងការរៀនភាសារបស់អ្នកស្ម័គ្រចិត្តនៅក្នុងសហគមន៍ និងជួយឲ្យអ្នកស្ម័គ្រចិត្តរបស់យើងមានសុវត្ថិភាព និងសុខភាពល្អ ខណៈពេលដែលពួកគេកំពុងផ្សារភ្ជាប់ទៅនឹងមនុស្សសំខាន់ៗដទៃទៀតនៅក្នុងសហគមន៍ពួកគេ។ មុនពេលបញ្ជូនអ្នកស្ម័គ្រចិត្តទៅរស់នៅ និងធ្វើការនៅសហគមន៍អចិន្ត្រៃយ៍របស់ពួកគេ ទីភ្នាក់ងារភីស ខ័រ បានរៀបចំសិក្ខាសាលា រយៈពេលមួយថ្ងៃស្តីអំពីពិធីសំណេះសំណាលជាមួយគ្រួសារខ្មែរជូនដល់អ្នកចូលរួមចំនួន ៧២ គ្រួសារ ដែលមានសមាជិកចូលរួមសរុប ១៥០នាក់ ដែលមកពីខេត្តបាត់ដំបង សៀមរាប ពោធិ៍សាត់ កំពង់ឆ្នាំង តាកែវ កំពត កំពង់ធំ ត្បូងឃ្មុំ កំពង់ចាម និងស្វាយរៀង។ ពិធីសំណេះសំណាលនេះ បានផ្តោតនិងពិភាក្សាលើប្រធានបទដូចជា ជំនាញប្រាស្រ័យទាក់ទងអន្តរវប្បធម៌ វប្បធម៌អាមេរិក ភាពចម្រុះពូជសាសន៍នៃជនជាតិអាមេរិកកាំង គោលនយោបាយរបស់ទីភ្នាក់ងារភីស ខ័រ និង ធ្វើយ៉ាងណាធានាឲ្យបាននូវសុខភាពនិងសុវត្ថិភាពរបស់អ្នកស្ម័គ្រចិត្ត។







ពិធីសំណេះសំណាលជាមួយគ្រួសារខ្មែរដែលនឹងទទួលអ្នកស្ម័គ្រចិត្តក្រុមទី១៥ នៅសណ្ឋាគារសាន់វ៉េ





## គំនិតផ្តួចផ្តើមថ្មី

### គម្រោងគាំទ្រកម្មវិធី អ្នកស្ម័គ្រចិត្តដើម្បីសហគមន៍ខ្ញុំ (ស.ស.ខ)

នៅឆ្នាំ ២០២១ ទីភ្នាក់ងារ ភីស ខ័រ កម្ពុជាបានចាប់ផ្តើមកិច្ចសហប្រតិបត្តិការជាមួយអគ្គនាយកដ្ឋានយុវជនរបស់ក្រសួងអប់រំ យុវជន និងកីឡា ដើម្បីគាំទ្រកម្មវិធីយុវអ្នកស្ម័គ្រចិត្តកម្ពុជាមួយ ដែលមានឈ្មោះថា អ្នកស្ម័គ្រចិត្តដើម្បីសហគមន៍ខ្ញុំ (ស.ស.ខ)។ ដើម្បីបង្ហាញពីការគាំទ្រចំពោះនាយកដ្ឋានគ្រប់គ្រងមជ្ឈមណ្ឌលយុវជន ក្នុងអំឡុងពេលមានការរីករាលដាលមេរោគកូវីដ-១៩ បុគ្គលិកយើងបានទៅធ្វើការអង្កេតមើលគម្រោងសហគមន៍ ដែលអនុវត្តកម្មវិធីអ្នកស្ម័គ្រចិត្តដើម្បីសហគមន៍ខ្ញុំ (ស.ស.ខ) នៅខេត្តសៀមរាប កំពង់ធំ កំពង់ចាម តាកែវ និងកំពត។ បុគ្គលិកយើងបានចូលរួមធ្វើជាគណៈកម្មការក្នុងសកម្មភាពវាយតម្លៃ និងជ្រើសរើសគម្រោងឆ្នើមប្រចាំខេត្ត នេះជាការប្រកួតផ្តាច់ព្រ័តថ្នាក់ជាតិ ដើម្បីជ្រើសរើសគម្រោងឆ្នើមជាក្រុមចំនួន ៦ គម្រោងក្នុងចំណោម ២៥ គម្រោង ហើយបុគ្គលិកយើងបានចូលរួមក្នុងពិធីប្រគល់រង្វាន់នៅក្នុងពិធីអបអរទិវាការងារស្ម័គ្រចិត្តអន្តរជាតិ ពីឆ្នាំ ២០២១ ដល់ឆ្នាំ ២០២៣។ បុគ្គលិកទីភ្នាក់ងារ ភីស ខ័រ ក៏បានផ្តល់វគ្គបណ្តុះបណ្តាលជូនអ្នកស្ម័គ្រចិត្ត ស.ស.ខ ស្តីពីការរៀបចំនិងគ្រប់គ្រងគម្រោង និងការអភិវឌ្ឍសួនដំណាំសហគមន៍ដើម្បីដោះស្រាយសន្តិសុខស្បៀង នៅសៀមរាប កំពង់ធំ និងបាត់ដំបង នៅឆ្នាំ ២០២២។








### សមិទ្ធផលសម្រេចបានពីគម្រោង

#### ឆ្នាំ ២០២២

- ទីភ្នាក់ងារ ភីស ខ័រ កម្ពុជាបានផ្តល់វគ្គបណ្តុះបណ្តាលថ្នាក់តំបន់ចំនួនបីស្តីពីការរៀបចំនិងការគ្រប់គ្រងគម្រោង និងសន្តិសុខស្បៀង ជូនអ្នកស្ម័គ្រចិត្ត ស.ស.ខ ចំនួន ៨១ នាក់ មកពីខេត្តចំនួន ៩។ សិក្ខាកាមដែលបានចូលរួមមកពីខេត្តតាកែវ កំពត កំពង់ឆ្នាំង បាត់ដំបង សៀមរាប កំពង់ធំ កំពង់ចាម ត្បូងឃ្មុំ និងខេត្តព្រៃវែង ដែលពួកគេជាបុគ្គលិកកម្មវិធី ស.ស.ខ នៅក្រសួង ចំនួន ១២ នាក់ និងអ្នកគ្រប់គ្រងកម្មវិធី ស.ស.ខ នៅក្នុងខេត្ត ចំនួន ១២នាក់ ។

#### ឆ្នាំ ២០២៣

- ទីភ្នាក់ងារ ភីស ខ័រ កម្ពុជាបានផ្តល់វគ្គបណ្តុះបណ្តាលស្តីពីការរៀបចំ និងការគ្រប់គ្រងគម្រោង ជូនអ្នកស្ម័គ្រចិត្ត ស.ស.ខ ចំនួន ៦៦នាក់ ដែលពួកគេមកពី ១១ ខេត្ត ព្រមទាំងអ្នកស្ម័គ្រចិត្តភីស ខ័រ ចំនួន ៣០ នាក់ ដែលកំពុងបម្រើការងារនាពេលបច្ចុប្បន្ន។ សិក្ខាកាមដែលបានចូលរួម មកពីខេត្តកំពង់ឆ្នាំង បាត់ដំបង បន្ទាយមានជ័យ សៀមរាប កំពង់ធំ កំពង់ចាម ត្បូងឃ្មុំ ព្រៃវែង តាកែវ និងកំពត ដែលពួកគេជាបុគ្គលិកកម្មវិធី ស.ស.ខ នៅក្រសួង ចំនួន ៦ នាក់ និងអ្នកគ្រប់គ្រងកម្មវិធី ស.ស.ខ នៅក្នុងខេត្តចំនួន ១១ នាក់។
- ជាលទ្ធផលក្រោយពីវគ្គបណ្តុះបណ្តាលស្តីពីការរៀបចំនិងការគ្រប់គ្រងគម្រោងបញ្ចប់ អ្នកស្ម័គ្រចិត្តភីស ខ័រ មួយចំនួនបានបំពេញការងាររួមគ្នាជាមួយអ្នកស្ម័គ្រចិត្តនៃកម្មវិធីអ្នកស្ម័គ្រចិត្តដើម្បីសហគមន៍ខ្ញុំ ដើម្បីចាប់ផ្តើមអនុវត្តគម្រោងនិងសកម្មភាពសហគមន៍រួមគ្នា។ យើងសង្ឃឹមថានឹងមានកិច្ចសហការរវាងអ្នកស្ម័គ្រចិត្តទាំងពីរកាន់តែច្រើនឡើងនៅពេលឆាប់ៗខាងមុខ!








វគ្គបណ្តុះបណ្តាលស្តីពីការរៀបចំនិងការគ្រប់គ្រងគម្រោង ជាមួយនឹងអ្នកស្ម័គ្រចិត្តដើម្បីសហគមន៍ខ្ញុំ






WELCOME TO
CAMBODIA




28th ANGKOR WAT INTERNATION
10Km




Peace Corps






Tel: 015 719 536


Parking



# ដំណើររឿងរបស់អ្នកស្ម័គ្រចិត្ត

## ម៉េហ្គិន ហ័រនឺរ (Megan Horner) និងអ្នកគ្រូ នីតា ដែលជាគ្រូដៃគូរបស់គាត់ នៅខេត្តកំពង់ធំ

អ្នកគ្រូដៃគូរបស់ខ្ញុំ ឈ្មោះនីតា យើងបានស្គាល់គ្នាដំបូងនៅពេលចូលរួមសិក្ខាសាលាស្តីពី កិច្ចសហការរវាងអ្នកស្ម័គ្រចិត្ត ភីស ខ័រ ជាមួយគ្រូដៃគូ ដែលបង្រៀននៅសាលាបឋមសិក្សា នាពេលចុងបញ្ចប់នៃវគ្គបណ្តុះបណ្តាលបឋម។ គាត់បានទិញតែគុជឲ្យខ្ញុំនៅពេលសម្រាកអាហារថ្ងៃត្រង់ ទាំងដែលខ្ញុំបានស្គាល់គាត់មិនទាន់បានបួនម៉ោងផង។បន្ទាប់មកក្រោយពេលខ្ញុំទៅដល់សហគមន៍ដែលខ្ញុំរស់នៅ និងបំពេញការងារ ខ្ញុំស្រឡាំងកាំងយ៉ាងខ្លាំងដោយជួបមនុស្សប្លែកមុខជាច្រើន ប៉ុន្តែ ខ្ញុំមានអារម្មណ៍ធូរស្រាលមកវិញនៅពេលដែលខ្ញុំបានឃើញ នីតា ឈរនៅខាងមុខថ្នាក់រៀនរបស់គាត់ស្វាគមន៍ខ្ញុំយ៉ាងកក់ក្តៅជាមួយនឹងស្នាមញញឹមដ៏រីករាយ។ គាត់បានជួយខ្ញុំរៀបចំកាលវិភាគបង្រៀន បង្កើតទម្លាប់ដើរលំហែជាមួយខ្ញុំ និងបានណែនាំខ្ញុំឲ្យស្គាល់ពីនំចំណីខ្មែរជាច្រើន។

ជានិច្ចជាកាល ការបង្រៀនជាមួយ នីតា មានលក្ខណៈសប្បាយរីករាយណាស់។ គាត់មិនត្រឹមតែជាអ្នកគ្រូដ៏អស្ចារ្យ និងសកម្មប៉ុណ្ណោះទេ ប៉ុន្តែ ថែមទាំងមានលក្ខណៈច្នៃប្រឌិតទៀតផង។ គាត់អាចនឹកឃើញល្បែងសិក្សាលេងភ្លាមៗ ឬបង្កើតសកម្មភាពសិក្សាយ៉ាងលឿនដើម្បីកុំឲ្យសិស្សយើងអផ្សុក។ ថ្វីបើនៅពេលដែលយើងមិនបង្រៀនក្តី ក៏យើងតែងតែជជែកគ្នាអំពីអនុស្សាវរីយ៍ល្អៗពេលដែលយើងបង្រៀនរួមគ្នា។

ប្រហែលជាមួយខែក្រោយពេលដែលខ្ញុំស្គាល់ នីតា ដំបូង គាត់បានស្នើខ្ញុំឲ្យធ្វើអ្នកកំដរកូនក្រមុំក្នុងថ្ងៃអពាហ៍ពិពាហ៍របស់គាត់។ គាត់បានប្រាប់ខ្ញុំថាការងារជាអ្នកកំដរកូនក្រមុំនេះ ជាធម្មតាគឺសម្រាប់អ្នកដែលជិតស្និទ្ធជាមួយកូនក្រមុំហើយគាត់បានបន្ថែមទៀតថាទោះបីជាយើងទើបតែស្គាល់គ្នាក៏ដោយក៏គាត់បានចាត់ទុកខ្ញុំជាមិត្តល្អបំផុតម្នាក់របស់គាត់ដែរ។ ដោយសារ





ខ្ញុំក៏បានចាត់ទុក នីតា ជាមិត្តល្អបំផុតម្នាក់របស់ខ្ញុំដែរខ្ញុំក៏បានយល់ព្រមភ្លាម។ ក្រៅពីធ្វើជាអ្នកកំដរកូនក្រមុំនីតាបានអនុញ្ញាតឲ្យខ្ញុំចូលរួមក្នុងសកម្មភាពផ្សេងទៀតជាច្រើនជាមួយគ្រួសារគាត់រួមមានដំណើរទៅលេងរាជធានីភ្នំពេញ ទីរួមខេត្តកំពង់ធំ រហូតដល់ប្រាសាទសំបូរព្រៃគុក។ នីតាមិនដែលអល់អែកក្នុងការហៅខ្ញុំចូលរួមដំណើរជាមួយគាត់ឡើយ។

មានពេលជាច្រើន ដែលខ្ញុំមានអារម្មណ៍អស់កម្លាំងចិត្តនៅក្នុងសហគមន៍ដែលខ្ញុំរស់នៅហើយសំណួរទីមួយដែលមនុស្សគ្រប់គ្នាសួរខ្ញុំ គឺ “តើ នីតា ដឹងឬទេ ? តើយើងគួរប្រាប់នីតាថាអ្នកមិនស្រួលខ្លួនឬទេ ?” និង “មកយើងនាំអ្នកទៅជួបនីតា” ទាំងនេះបង្ហាញពី មិត្តភាពជ្រាលជ្រៅរវាងខ្ញុំនិង នីតា។ មិនត្រឹមតែសិស្សទេដែលដឹង សូម្បីតែសមាជិកសហគមន៍ក៏បានដឹងពីមិត្តភាពដ៏ជិតស្និទ្ធរបស់យើងដែរ។

នីតា និង ខ្ញុំជារឿយៗបង្ហាញពីអំណរគុណរបស់យើងទៅវិញទៅមកតាមរយៈកាហ្វេ។ ជួនកាល នៅពេលឈប់សម្រាករបស់យើង នីតា ទៅទិញកាហ្វេពីហាងមួយនៅក្នុងស្រុករបស់យើង។ នៅថ្ងៃឈប់សម្រាករបស់ខ្ញុំ ខ្ញុំជិះកង់ទៅហាងកាហ្វេដដែលនោះ ទិញកាហ្វេសម្រាប់យើងទាំងពីរនាក់ ហើយជិះកង់ត្រឡប់ទៅសាលាដើម្បីញ៉ាំកាហ្វេជាមួយគ្នា។ សូម្បីតែពេលយើងធ្វើដំណើរចេញក្រៅសហគមន៍យើងក្តី ក៏ម្នាក់ក្នុងចំណោមយើងទាំងពីរតែងតែព្យាយាមទិញកាហ្វេឲ្យគ្នាដែរ។ បច្ចុប្បន្ននេះ រាល់ពេលដែលខ្ញុំញ៉ាំកាហ្វេ ខ្ញុំតែងតែងនឹកដល់ នីតា ហើយខ្ញុំ ញ៉ាំកាហ្វេយ៉ាងច្រើន!



## អេថិន ស្មីត (Ethan Smith) និងសិស្សរបស់គាត់នៅខេត្តកំពង់ចាម



នៅកម្ពុជា ខ្ញុំរស់នៅក្នុងទីរួមខេត្តដែលនៅទីនោះមានបញ្ហាប្រឈមខុសគ្នាទៅនឹងតំបន់ដទៃទៀតដែលនៅឆ្ងាយពីទីរួមខេត្ត រួមមានការបង្កើតទំនាក់ទំនងជាមួយសមាជិកនៅក្នុងសហគមន៍។ ពីរបីសប្តាហ៍ដំបូងនៅក្នុងសហគមន៍ដែលខ្ញុំរស់នៅ ខ្ញុំមិនសូវស្គាល់មនុស្សច្រើនទេក្រៅពីគ្រួសារម្ចាស់ផ្ទះ និង គ្រូដៃគូរបស់ខ្ញុំនៅសាលាគរុកោសល្យ និងវិក្រឹតការខេត្ត។ មិនខុសពីស្ថានភាពថ្មីៗដែលខ្ញុំបានជួបប្រទះក្នុងជីវិត ខ្ញុំអៀនច្រើន និងមិនសូវចេះរាក់ទាក់ជាមួយមនុស្សនៅជុំវិញខ្ញុំទេ។ ខ្ញុំមានភាពរាក់ទាក់និងស្និទ្ធស្នាលនៅពេលបង្រៀន ដែលវាមានលក្ខណៈផ្ទុយគ្នាស្រឡះពេលនៅក្រៅថ្នាក់រៀន។ ប៉ុន្តែ មានគរុសិស្សមួយចំនួនតូចបានសាកសួរខ្ញុំអំពីការចាប់ផ្តើមក្លឹបរៀនភាសាអង់គ្លេស មួយនៅសាលាគរុកោសល្យ និងវិក្រឹតការខេត្ត។ ខ្ញុំបានឯកភាពភ្លាមថា នឹងចាប់ផ្តើមក្លឹបនេះជាមួយគរុសិស្សទាំងនេះដែលមានអាយុស្រាលខ្ញុំដែរ ដោយមានអ្នកខ្លះអាយុយ៉ាងច្រើនប្អូនខ្ញុំពីរបីឆ្នាំ។ នៅពេលខ្ញុំចាប់ផ្តើមដំណើរការក្លឹប និងបន្តបង្រៀន គរុសិស្សទាំងនេះបានស្គាល់ខ្ញុំកាន់តែច្បាស់ហើយខ្ញុំមានអារម្មណ៍សុខស្រួល ហើយបន្តិចម្តងៗខ្ញុំបានចាប់ផ្តើមមានអារម្មណ៍ជឿជាក់លើខ្លួនឯង។ គរុសិស្សស្នូលមួយក្រុមមានប្រាំនាក់បានក្លាយជាអ្នក ដែលបានច្នៃសាលាខ្ញុំឲ្យក្លាយទៅជា សហគមន៍ពិតមួយរបស់ខ្ញុំ។ ពួកគេបានជួយផ្សារភ្ជាប់ទំនាក់ទំនងរវាងខ្ញុំ និងគរុសិស្ស ដែលមិនមានជំនាញភាសាអង់គ្លេសចាំបាច់ សម្រាប់ធ្វើការប្រាស្រ័យទាក់ទងជាមួយខ្ញុំ ឲ្យមានចំនួនកាន់តែច្រើនឡើង។ ការណ៍នេះ មិនត្រឹមតែនាំឲ្យទំនាក់ទំនងរបស់ខ្ញុំជាមួយសិស្សកាន់តែប្រសើរឡើងប៉ុណ្ណោះទេ ប៉ុន្តែ នាំឲ្យខ្ញុំអាចបង្កើនការប្រើប្រាស់ភាសាខ្មែរនៅសាលាទៀតផង។

នៅពេលដែលឆ្នាំសិក្សាដំណើរការសិស្សទាំងនេះបានអញ្ជើញខ្ញុំចូលរួមព្រឹត្តិការណ៍សាលាដំណើរកំសាន្ត និងចូលរួមពិសាអាហារពេលល្ងាចជាមួយពួកគេ។ ព្រឹត្តិការណ៍ដែលគួរអោយចងចាំបំផុតគឺ ដំណើរកំសាន្តរយៈពេលបីថ្ងៃទៅប្រាសាទអង្គរវត្ត និងខេត្តសៀមរាបជាមួយគរុសិស្សភាគច្រើន និង លោកគ្រូ អ្នកគ្រូមួយចំនួនទៀត។ នៅក្នុងឆ្នាំសិក្សាទាំងមូលពួកគេបានជួយខ្ញុំរកកន្លែងល្អៗសម្រាប់ហូបអាហារ កន្លែងសម្រាកកំសាន្ត កន្លែងកាត់ដេរសម្លៀកបំពាក់ និងកន្លែងផ្សេងៗជាច្រើនទៀត។ ទន្ទឹមនឹងនេះដែរខ្ញុំបានរៀនសូត្រយ៉ាងច្រើន អំពីប្រទេសកម្ពុជាតាមរយៈការសន្ទនារបស់ខ្ញុំជាមួយសិស្សានុសិស្ស ដែលរាប់ចាប់តាំងពីចំណុចតូចតាចដូចជា របៀបដែលក្រសួងអប់រំធ្វើការ រហូតដល់កិច្ចការប្រចាំថ្ងៃនិងផ្ទាល់ខ្លួន។ ខ្ញុំបានស្គាល់សិស្សានុសិស្សជាច្រើនលើសពីអ្នកស្ម័គ្រចិត្តភីស ខ័រ ដទៃទៀតនិងគ្រួសារខ្មែររបស់ខ្ញុំ។ ខ្ញុំថែមទាំងបានចូលរួមបុណ្យសពម្តាយរបស់សិស្សខ្ញុំម្នាក់ដែលនេះ ជាបទពិសោធន៍រំជួលចិត្តដ៏លំបាកមួយ។ ទោះជាយ៉ាងណាក៏ដោយ ក៏ខ្ញុំរីករាយដែលខ្ញុំបានចូលរួមពិធីបុណ្យសពនេះ ដើម្បីបង្ហាញពីការគាំទ្ររបស់ខ្ញុំចំពោះសិស្សរូបនេះ។





នៅពេលដែលខ្ញុំចាប់ផ្តើមបង្រៀននៅសាលាគរុកោសល្យនិងវិក្រឹតការខេត្តនោះគឺជាឆ្នាំសិក្សាចុងក្រោយសម្រាប់គរុសិស្សនាជំនាន់នោះ។ ពួកគេទាំងអស់បានបញ្ចប់ការសិក្សា ហើយបច្ចុប្បន្នពួកគេ កំពុងបង្រៀននៅសាលាបឋមសិក្សានៅខេត្តកំពង់ចាម និងខេត្តត្បូងឃ្មុំ។ ខ្ញុំមានអារម្មណ៍ក្រៀមក្រំផងនិងរីករាយផងនៅពេលដែលសិស្សបានចាកចេញដើម្បីចាប់ផ្តើមអាជីពបង្រៀនរបស់ពួកគេ។ ខ្ញុំរីករាយដែលពួកគេទាំងអស់អាចបញ្ចប់ការសិក្សា និងក្លាយជាគ្រូបង្រៀន ស្របពេលដែលមានអារម្មណ៍ក្រៀមក្រំពេលពួកគេលែងជាសិស្សដ៏ល្អរបស់ខ្ញុំទៀតហើយ។ ខ្ញុំនៅរក្សាទំនាក់ទំនងជាមួយសិស្សមួយចំនួន តាមរយៈសារជាអក្សរឬជជែកគ្នាលេងប្រសិនបើខ្ញុំជួបពួកគេនៅទីរួមខេត្ត។ ម្យ៉ាងទៀតអតីតសិស្សរបស់ខ្ញុំម្នាក់នៅពេលនេះ គឺជាមិត្តល្អបំផុតរបស់ខ្ញុំ និងគឺជាអ្នកដែលបានធ្វើឲ្យបទពិសោធន៍ការងារនៅ ភីស ខ័រ របស់ខ្ញុំមានលក្ខណៈអស្ចារ្យ និងគួរឲ្យចងចាំ។ ខ្ញុំជឿជាក់នៅក្នុងជម្រៅបេះដូងរបស់ខ្ញុំថា ប្រសិនបើខ្ញុំមិនបានជួបមនុស្សដ៏អស្ចារ្យទាំងនេះទេ នោះដំណើររឿងនៅក្នុងការងារភីស ខ័រ របស់ខ្ញុំមុខជាមានលក្ខណៈខុសគ្នាទាំងស្រុង ហើយប្រហែលជាមិនសូវមានឥទ្ធិពលសម្រាប់រូបខ្ញុំផ្ទាល់និងអ្នកនៅជុំវិញខ្ញុំឡើយ។ ពេលនេះ ខ្ញុំរង់ចាំយ៉ាងអន្ទះសារនូវការមកដល់នៃគរុសិស្សជំនាន់ថ្មីដើម្បីចាប់ផ្តើមការសិក្សានៅសាលាគរុកោសល្យ និងវិក្រឹតការខេត្ត។ ខ្ញុំរំពឹងថានឹងបង្កើតអនុស្សាវរីយ៍និងទំនាក់ទំនងកាន់តែច្រើនថែមទៀតនៅទីនេះនៅកម្ពុជា។



## ខេធី អូស៊ូលីវ៉ិន (Katie O'Sullivan) និងក្លឹបភាសាអង់គ្លេសក្រៅម៉ោងសិក្សារបស់គាត់នៅខេត្តបន្ទាយមានជ័យ

ក្លឹបភាសាអង់គ្លេសក្រៅម៉ោងសិក្សាដែលសិស្សក្នុងសហគមន៍ខ្ញុំបានចាប់ផ្តើម គឺជាក្តីរីករាយនិងចំណូលចិត្តរបស់ខ្ញុំនៅទីនេះក្នុងប្រទេសកម្ពុជា។ ដោយមានលក្ខណៈជារចនាសម្ព័ន្ធ ដឹកនាំដោយសិស្ស និងអន្តរមុខវិជ្ជា ក្លឹបនេះបានបំពេញមុខងារយ៉ាងច្រើនផ្សេងទៀតលើសពីសិស្សសិក្សាភាសាអង់គ្លេស។ វាគឺជាកន្លែងមួយដែលសិស្សជួបជុំគ្នាដើម្បីរៀនសូត្រពីគ្នា ធ្វើការរួមគ្នា និងរកឃើញក្តីរំភើប និងការលើកទឹកចិត្តក្នុងការប្រើប្រាស់និងកែលម្អជំនាញភាសាអង់គ្លេសរបស់ពួកគេ។ យើងអនុវត្តការប្រើប្រាស់ភាសាអង់គ្លេសតាមរយៈល្បែងសិក្សានិងសកម្មភាពសិក្សាជាជាងការសិក្សាតាមសៀវភៅ និងការធ្វើតេស្តហើយយើងប្រើភ្លេង សិល្បៈ និងដំណើរកំសាន្តដើម្បីប្រើប្រាស់ភាសានេះក្នុងសេណារីយ៉ូ ជាក់ស្តែងក្នុងជីវិត។

ក្លឹបនេះបានចាប់ផ្តើមដោយការបង្រៀនរបស់ខ្ញុំ ទៅកាន់បងប្អូនធម៌ ពីរនាក់របស់ខ្ញុំមុនពេលបាយល្ងាច ហើយបានរីកលូតលាស់ទៅជាក្លឹបមួយដែលមានសិស្សប្រហែល ៥០ នាក់ និងមេរៀនដែលយើងរៀនស្តីពីការប្រារព្ធពិធីបុណ្យហាឡូវីន និងការធ្វើប័ណ្ណជូនពរថ្ងៃបុណ្យ រហូតដល់ការទៅលេងប្រាសាទដែលនៅជិតនោះ និងការពិភាក្សាអំពីប្រពៃណីនិងទំនៀមទម្លាប់ក្នុងមូលដ្ឋានជាដើម។

យើងទាំងអស់គ្នា បានបង្កើតបរិស្ថានមួយ ដែលបុគ្គលម្នាក់ៗមានអារម្មណ៍សុខស្រួល អបអរសាទរ និងទទួលបាននូវការគាំទ្រ មិនរុញរាក្នុងការសាកល្បងអ្វីដែលថ្មី និង ត្រូវបានលើកទឹកចិត្តឲ្យមានភាពក្លាហាន។ ចំណុចនេះ រួមមានទាំងរូបខ្ញុំដែលជា "គ្រូបង្រៀន" ផងដែរ។ ក្លឹបនេះ បានជួយឲ្យខ្ញុំអាចរកឃើញទីកន្លែងរបស់ខ្ញុំនៅក្នុងសហគមន៍ និងផ្សារភ្ជាប់ជាមួយសិស្សលើសពីគ្រាន់តែ ជាថ្នាក់រៀនមួយ។ ជាលទ្ធផល ខ្ញុំមានមនោសញ្ចេតនាដ៏ជ្រាលជ្រៅជាមួយសិស្សទាំងនេះ និងចាត់ទុកពួកគេដូចជាគ្រួសារតែមួយ។ ក្តីសប្បាយរីករាយដែលខ្ញុំមានក្រោយពេលចេញពីសាលាគឺនៅពេលដែលសិស្សទាំងនេះមកដល់ពោរពេញដោយថាមពល និងមានចិត្តចង់រៀន។ ការមើលឃើញភាសាអង់គ្លេសរបស់ពួកគេមានការរីកចម្រើនជាមួយរាល់មេរៀនដែលបានរៀន គឺមានលក្ខណៈពិសេស ប៉ុន្តែផ្នែកដែលល្អប្រសើរបំផុតនៃការងាររបស់ខ្ញុំ គឺការមើលឃើញពួកគេមានសេចក្តីក្លាហាន និងរកឃើញសំឡេងរបស់ពួកគេ។

គ្រួសារខ្មែរខ្ញុំ មានតួនាទីយ៉ាងសំខាន់ចំពោះភាពជោគជ័យនៃក្លឹបរបស់យើង។ នៅពេលដែលគ្រួសារខ្មែរខ្ញុំឃើញពីការរីកនៃទំហំក្លឹបនេះ ពួកគាត់មានចិតសប្បុរសបានផ្តល់ឲ្យយើងនូវកន្លែងមួយដើម្បីជួបជុំគ្នារៀន និងធ្វើការក្រុម។ រួមគ្នាជាមួយសិស្ស យើងបានតុបតែងកន្លែងនេះ និងមានផែនការគូររូបលើជញ្ជាំងមួយនាពេលអនាគត។ គ្រួសារខ្មែរខ្ញុំ បានវិនិយោគយ៉ាងច្រើនទៅលើសហគមន៍មូលដ្ឋានរបស់យើង ហើយក្តីស្រឡាញ់របស់ពួកគាត់ចំពោះក្មេងៗ គឺអាចមើលឃើញច្បាស់តាមរយៈការជួយបង្កើត និងថែរក្សាក្លឹបនេះអោយនៅស្ថិតស្ថេរ។ បើគ្មានក្តីស្រឡាញ់និងការគាំទ្ររបស់ពួកគាត់ទេ នោះកិច្ចការនេះពិតជាមិនអាចធ្វើបានឡើយ។ ប្អូនស្រីធម៌ខ្ញុំឈ្មោះសារី គឺជាឆ្អឹងខ្នងសំខាន់នៃកិច្ចខិតខំប្រឹងប្រែងនេះទាំងមូល។ គាត់មិនត្រឹមតែធ្វើការជាមួយខ្ញុំដើម្បីបង្រៀនភាសាអង់គ្លេសដល់សិស្សប៉ុណ្ណោះទេ ប៉ុន្តែ ថែមទាំងជួយបំពេញចន្លោះប្រហោងខាងវប្បធម៌និងភាសារវាងសិស្ស និងរូបខ្ញុំទៀតផង។

ដោយឆ្លុះបញ្ចាំងអំពីអ្វីដែលយើងបានបង្កើត ខ្ញុំមានសេចក្តីស្ញប់ស្ញែងក្រៃលែង។ សិស្សទាំងនោះ សមនឹងទទួលបានការទទួលស្គាល់ពេញលេញសម្រាប់គម្រោងនេះ។ ពួកគេបានមកដោយឆន្ទៈរបស់ពួកគេខ្លួនឯង បានសម្រេចចិត្តថាតើក្លឹបនេះត្រូវមានទម្រង់បែបណា និងបានជួយរៀបចំផែនការប្រធានបទមេរៀនសម្រាប់សប្តាហ៍នីមួយៗ។ ពួកគេគឺវៃឆ្លាត មានសេចក្តីក្លាហាន និងចិត្តល្អ។ ពួកគេជំរុញទឹកចិត្ត ខ្ញុំឲ្យក្លាយជាគ្រូល្អបំផុតម្នាក់ដែលអាចធ្វើបានរាល់ថ្ងៃ ដើម្បីពួកគេ។ ខ្ញុំបានបង្រៀនភាសាអង់គ្លេសដល់ពួកគេ ប៉ុន្តែ មេរៀនដែលពួកគេបានបង្រៀនខ្ញុំ និងក្តីស្រឡាញ់ដែលពួកគេបានផ្តល់ឲ្យខ្ញុំ គឺស្មើនឹងបីដង។











# ជេក អាប់ថិន (Jake Upton) និងបទពិសោធន៍ជាមួយគ្រួសារខ្មែរ និងសហគមន៍នៅខេត្តកំពង់ឆ្នាំង



ខ្ញុំជួបជាមួយគ្រួសារខ្មែររបស់ខ្ញុំដំបូងគឺហាក់បីដូចជាខ្យល់ក្ដួចពោរពេញដោយអារម្មណ៍ច្របូកច្របល់លាយជាមួយក្ដីរំភើបនិងកង្វល់។ ខ្ញុំមានត្រឹមតែព័ត៌មានស្រពិចស្រពិលអំពីជីវប្រវត្តិគ្រួសារខ្មែរខ្ញុំពីកញ្ចប់ព័ត៌មានស្ដីពីកន្លែងដែលខ្ញុំត្រូវទៅរស់នៅនិងបំពេញការងារ និងរូបថតផ្ទះប៉ុន្មានសន្លឹកដែលមិនសូវច្បាស់ដើម្បីស្មានមើលថាតើរយៈពេលពីរឆ្នាំខាងមុខនៃជីវិតខ្ញុំនឹងមានដំណើរដូចម្ដេច។

បន្ទាប់មក ស្រាប់តែខ្ញុំនៅទីនោះដោយអង្គុយនៅតុបាយជាមួយគ្រួសារថ្មីរបស់ខ្ញុំ។ មុននឹងខ្ញុំបានដឹងអំពីស្ថានភាពរស់នៅរបស់ខ្ញុំ យើងបានសើចសប្បាយ និងនិយាយលេងជាមួយគ្នា ជាមួយនឹងការចែករំលែកអាហារនិងការសន្ទនាគ្នាលេងជាលក្ខណៈគ្រួសារ។ ជីដូនធម៌ខ្ញុំទទូចឲ្យខ្ញុំហៅគាត់ថាម្ដាយហើយហៅម្ដាយ និងឪពុកធម៌របស់ខ្ញុំថាបងប្រុស និងបងស្រី។ ភាពកក់ក្ដៅនិងភាពរាក់ទាក់របស់ពួកគាត់បានធ្វើឲ្យក្ដីកង្វល់របស់ខ្ញុំលាយបាត់អស់ហើយខ្ញុំដឹងដោយគ្មានសង្ស័យថាខ្ញុំនឹងពេញចិត្តរស់នៅជាមួយពួកគាត់សម្រាប់រយៈពេលពីរឆ្នាំខាងមុខ។

ជិតមួយឆ្នាំបានកន្លងផុតទៅហើយចាប់តាំងពីថ្ងៃនោះ ហើយខ្ញុំពិតជាគិតត្រូវមែននៅពេលនោះ។ គ្រួសារខ្មែររបស់ខ្ញុំបានរួមដំណើរជាមួយខ្ញុំរាល់ជំហាននៅតាមមាគ៌ានេះដោយជួយខ្ញុំក្នុងការបញ្ជ្រាបខ្លួនចូលទៅក្នុងសហគមន៍ នាំខ្ញុំទៅចូលរួមពិធីបុណ្យ ជប់លៀង និងព្រឹត្តិការណ៍ផ្សេងៗ។

ឪពុកធម៌ខ្ញុំគឺជាគ្រូបឋមសិក្សាដូចខ្ញុំដែរហើយជារឿយៗយើងជជែកគ្នាអំពីការបង្រៀន និងឈប់សម្រាកក្រោយពេលធ្វើការពេញមួយថ្ងៃ។ គាត់ចូលចិត្តជិះកង់ ហើយយើងជិះកង់ជាមួយគ្នាយ៉ាងញឹកញាប់នៅពេលល្ងាច។ ក្នុងអំឡុងពេលដែលខ្ញុំរស់នៅជាមួយគាត់គាត់ក៏បានជួយខ្ញុំដោះស្រាយបញ្ហាទាក់ទងនឹងកង់របស់ខ្ញុំច្រើនរាប់មិនអស់ ចំណែកឯខ្ញុំបានព្យាយាមជួយគាត់លើភាសាអង់គ្លេស និងបញ្ហាបច្ចេកវិទ្យាព័ត៌មាន កុំព្យូទ័រឬម៉ាស៊ីនព្រីនរបស់គាត់។ គាត់ចូលចិត្តហៅខ្ញុំទៅចូលរួមពិធីជប់លៀងជាមួយមិត្តភក្ដិគាត់ និងបានជួយខ្ញុំឲ្យចេះលេងប៊ូលបានល្អឡើង។ ថ្វីបើខ្ញុំមិនមែនជាដៃគូលេងប៊ូលដ៏ល្អ ប៉ុន្តែ គាត់នៅតែចូលចិត្តលេងជាមួយខ្ញុំ។

ម្ដាយធម៌ខ្ញុំធ្វើការនៅក្រសួងវប្បធម៌ ថ្វីបើជានៅពេលខ្ញុំទើបមកដល់ដំបូងគាត់ធ្វើការនៅក្រសួងសាធារណការក្ដី។ គាត់បានណែនាំខ្ញុំឲ្យស្គាល់អ្នកបម្រើការនិងមន្ត្រីក្រសួងជាច្រើននាក់ខ្ញុំជឿថាមកទល់ពេលនេះខ្ញុំបានជួបមន្ត្រីការិយាល័យនៃខេត្តកំពង់ឆ្នាំងជាងពាក់កណ្ដាលហើយ។

ប្អូនប្រុសធម៌ខ្ញុំ ក៏ធ្វើការនៅសាលាខេត្តកំពង់ឆ្នាំងដែរ។ គាត់គឺជាសមាជិករវល់បំផុតនៃគ្រួសារខ្ញុំជារឿយៗគាត់ត្រឡប់មកផ្ទះវិញនាពេលយប់ជ្រៅក្រោយពេលសរសេរឯកសារមួយថ្ងៃពេញ។ ជាធម្មតាខ្ញុំបានជួបគាត់នៅពេលដែលយើងទាំងពីរនាក់អង្គុយញ៉ាំបាយល្ងាចនៅពេលយប់ជ្រៅ ពេលដែលខ្ញុំចេញពីបង្រៀនលោកនេននៅវត្តជិតផ្ទះនាថ្ងៃខ្លះក្នុងសប្ដាហ៍ ។ យើងទាំងអស់គ្នាជជែកអំពីការងារដែលយើងបានធ្វើពេញមួយថ្ងៃកន្លងមក និងរៀនប្រើភាសាអង់គ្លេសនិងខ្មែរ នៅពេលកំពុងញ៉ាំបាយកក។ គាត់ក៏ដូចម្ដាយគាត់ដែរ គាត់បានណែនាំខ្ញុំឲ្យស្គាល់មន្ត្រីការិយាល័យរាប់មិនអស់។







ពេលទៅវត្តជាមួយគ្រួសារម្ចាស់ផ្ទះ

នៅពេលខ្ញុំទើបមកដល់ដំបូង ខ្ញុំមិនទាំងដឹងថាខ្ញុំមានប្អូនស្រីធម៌ម្នាក់ទៀតទេក្នុងអំឡុងពេលដែលខ្ញុំរស់នៅទីនេះគាត់ភាគច្រើនរស់នៅភ្នំពេញ ដើម្បីបន្តការសិក្សា ឬ កំពុងធ្វើការនៅកន្លែងការងារថ្មីរបស់គាត់នៅពេលថ្មីៗនេះ។ ថ្វីបើខ្ញុំមិនបានជួបគាត់ច្រើនក្ដី ក៏គាត់តែងតែមកផ្ទះនៅពេលឈប់សម្រាកបុណ្យដែរ ដូច្នេះ នៅពេលណាដែលគាត់មក ខ្ញុំដឹងថាគ្រួសារខ្ញុំនឹងរៀបចំពិធីអ្វីមួយហើយ ថ្វីបើខ្ញុំមិនដឹងថាជាពិធីអ្វីក៏ដោយ។ ភាសាអង់គ្លេសរបស់គាត់គឺល្អណាស់ ហើយជារឿយៗ គាត់ជួយពន្យល់ខ្ញុំនូវចំណុចពិបាកៗនៅក្នុងការសន្ទនាគ្នា។

ជាចុងក្រោយៈ ជីដូនធម៌ខ្ញុំ។ មុនពេលគាត់ចូលនិវត្តន៍ គាត់ធ្លាប់ធ្វើជានាយិកាសាលាដែលខ្ញុំបង្រៀន។ គាត់ស្គាល់គ្រូនិងបុគ្គលិកសាលាទាំងអស់យ៉ាងច្បាស់ និងចូលចិត្តស្ដាប់ខ្ញុំនិយាយអំពីអ្វីដែលកំពុងកើតឡើងនៅសាលា។ គាត់តែងតែជំរុញឲ្យខ្ញុំញ៉ាំអាហារឲ្យបានច្រើនតាមដែលមនុស្សទូទៅអាចហូបបាន និងសង្កេតមើលយ៉ាងមធ្យ័តក្រែងលោខ្ញុំមានសញ្ញាឈឺថ្កាត់តិចតួចក្ដី។ គាត់ចូលចិត្តនាំខ្ញុំទៅបុណ្យនៅតាមវត្តផ្សេងៗ និងចូលរួមពិធីជប់លៀង និងព្រឹត្តិការណ៍ផ្សេងៗ ។ នៅពេលណាខ្ញុំបោកគក់



អ៊ុតខោអាវ លាងចាន ឬធ្វើកិច្ចការផ្សេងៗទៀតនៅជុំវិញផ្ទះ គាត់តែងតែមកមើលដើម្បីជួយ និងផ្តល់ដំបូន្មានឲ្យខ្ញុំ។

ខ្ញុំមានពេលវេលា និងថាមពលដើម្បីចូលរួមយ៉ាងជ្រៅជាមួយសហគមន៍ និងវប្បធម៌ខ្មែរ ទាំងនេះជាជំនួយនិងការគាំទ្រដែលគ្រួសារខ្មែរខ្ញុំ បានផ្តល់ឲ្យខ្ញុំ។ រាល់ថ្ងៃច័ន្ទ ពុធ និងសុក្រ ខ្ញុំជិះកង់ទៅបង្រៀនភាសាអង់គ្លេសជូនលោកនេនដែលរស់នៅលើកំពូលភ្នំនៅជិតផ្ទះ។ បន្ទាប់មក ខ្ញុំទៅផ្ទះគ្រូដៃគូខ្ញុំដើម្បីរៀនភាសាខ្មែរ។ បើទោះជាខ្ញុំត្រឡប់មកផ្ទះវិញយប់ក្តី ក៏គ្រួសារខ្ញុំតែងតែប្រាកដថាមានអាហារក្តៅៗនៅរង់ចាំខ្ញុំដែរ។ ការបង្រៀនព្រះសង្ឃ បានអនុញ្ញាតឲ្យខ្ញុំកសាងបាននូវទំនាក់ទំនងសហគមន៍ដ៏មានតម្លៃ ពីការជជែកជាមួយសមាជិកសហគមន៍ជាច្រើនដែលទៅវត្ត ហើយបានបង្កើនកេរ្តិ៍ឈ្មោះខ្ញុំនៅក្នុងសហគមន៍ជិតខាង រហូតដល់វត្តផ្សេងទៀតបានស្នើសុំឲ្យខ្ញុំទៅបង្រៀនដែរ។



បង្រៀនលោកនេន



ហាត់ក្បាច់គុនខ្មែរល្បុក្កតោ

នៅពេលទំនេរ ខ្ញុំហាត់ក្បាច់គុនខ្មែរល្បុក្កតោ។ ខ្ញុំហាត់រៀនរៀងរាល់ចុងសប្តាហ៍និងធ្វើការសម្តែងបង្ហាញជាមួយសិស្សល្បុក្កតោដទៃផ្សេងទៀត។ ខ្ញុំបានសិក្សាច្រើនអំពីប្រវត្តិសាស្រ្តនិងវប្បធម៌ខ្មែរ ដោយសិក្សាជាមួយពួកគេ និងបានចែករំលែកជាមួយពួកគេនូវចំណេះដឹងរបស់ខ្ញុំផ្ទាល់អំពីក្បាច់គុនតៃក្វាន់ដូ និងការបោកចំបាប់បែបលោកខាងលិច។ “លោកគ្រូ” របស់ខ្ញុំ (ដែលបកប្រែត្រង់ថាជាគ្រូបង្រៀន ប៉ុន្តែ ក្នុងបរិបទនេះ ប្រហែលជាបកប្រែបានល្អបំផុតថាជា សេនសេ) ក៏គឺជាអ្នកបោកចំបាប់ម្នាក់ដ៏ចំណាប់ចំនួនដែរ។ យូរៗម្តង គាត់ឲ្យខ្ញុំដឹកនាំសិស្សថ្មីខ្លះ តាមរយៈការហាត់ក្បាច់គុនល្បុក្កតោពួកគេ ឬរហូតដល់ឲ្យខ្ញុំបង្រៀនពួកគេនូវអ្វីក៏ដោយដែលខ្ញុំចង់។ គ្រួសារម្ចាស់ផ្ទះខ្ញុំបានជួយគាំទ្រការហាត់ក្បាច់គុនល្បុក្កតោរបស់ខ្ញុំយ៉ាងខ្លាំង ដោយម្តាយធម៌ខ្ញុំសុខចិត្តចំណាយពេលដេរក្រណាត់រុំដៃឲ្យខ្ញុំដើម្បីប្រើ ក្រោយពេលដែលក្រញូវដៃខ្ញុំកោសរលាត់ស្បែកបន្តិចក្នុងពេលហាត់។





នៅពេលខ្ញុំនៅភ្នំពេញដើម្បីចូលរួមប្រជុំគណៈកម្មាធិការមួយ ខ្ញុំបានទទួលដំណឹងអាក្រក់ថាជីដូនធម៌ខ្ញុំបានធ្លាក់ខ្លួនឈឺ និងត្រូវបានបញ្ជូនទៅមន្ទីរពេទ្យ។ សំណាងល្អ គាត់ស្ថិតក្នុងស្ថានភាពនឹងនរ ហើយក្រោយពេលដើររកមើលក្នុងមន្ទីរពេទ្យ ខ្ញុំបានជួបគាត់។ ខ្ញុំបានសួរគាត់ដដែលៗថាតើមានអ្វីដែលខ្ញុំអាចធ្វើបាន វិធីអ្វីដែលខ្ញុំអាចជួយបានឬទេ ប៉ុន្តែ កង្វល់តែមួយគត់របស់គាត់គឺថាជំងឺរបស់គាត់បានធ្វើឲ្យដៃរបស់គាត់ចុះខ្សោយ ហើយគាត់មិនដឹងថាតើគាត់នឹងអាចដាំស្លឲ្យខ្ញុំបានឬទេ។ គាត់បានប្រាប់ខ្ញុំទាំងទឹកភ្នែកថាប្រសិនបើខ្ញុំត្រូវដូរទៅគ្រួសារផ្សេងមួយទៀតនោះគាត់ថាមិនអីទេ។ ខ្ញុំបានប្រាប់គាត់ថាខ្ញុំមិនចង់ទៅណាទេ បើទោះបីជាខ្ញុំត្រូវដាំស្លដោយខ្លួនខ្ញុំរាល់ពេលបាយក៏ដោយ។

សំណាងល្អ រឿងរ៉ាវមិនអាក្រក់ដូចដែលយើងបារម្ភទេ។ គាត់បានជាវិញ ហើយមីងជាប់ផ្ទះម្នាក់បានស្ម័គ្រចិត្តជួយដាំស្ល។ ខ្ញុំរំភើបយ៉ាងខ្លាំងចំពោះការយកចិត្តទុកដាក់របស់គាត់ចំពោះខ្ញុំ សូម្បីតែនៅក្នុងកាលៈទេសៈដ៏លំបាកបំផុតក្តី។ ខ្ញុំនឹងដឹងគុណចំពោះសេចក្តីស្រឡាញ់និងការគាំទ្ររបស់គ្រួសារខ្មែរខ្ញុំជារៀងរហូត ហើយខ្ញុំជាប់ជំពាក់គុណពួកគាត់ច្រើនណាស់សម្រាប់ភាពជោគជ័យជាអ្នកស្ម័គ្រចិត្តភីស ខ័រមួយរូប។


















Teacher Victoria
My name is
I am 10




Friday
Temple



**ទីស្នាក់ការ ពីស ខ័រ កម្ពុជា**

ផ្ទះលេខ ៧អា ផ្លូវលេខ ២៥៦

រាជធានីភ្នំពេញ ប្រអប់សំបុត្រលេខ ២៤៥៣

ទូរស័ព្ទលេខ៖ (៨៥៥) ២៣ ២២២ ៩០១

ទូរសារលេខ៖ (៨៥៥) ២៣ ២២២ ៩០៣

អ៊ីម៉ែល៖ KH-WebInfo@peacecorps.gov

**ស្វែងរកយើងតាមរយៈ៖**